**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Feb-2012, 10:47
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ:**
**ឧបសម្ព័ន្ធ ក&ខ ជាការសម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជូនអង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុសាក្សីនៃសំណុំរឿង ០០២ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយអនុវត្តតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង E127/4

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហចៅក្រមស៊ើបអង្កេត:**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Laurent KASPER-ANSERMET

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក គង់ សំអុន

លោក Arthur VERCKEN

លោក Jacques VERGÈS

# ការបង្ហាញ

១. នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើឱ្យមានសេចក្តីបង្គាប់ពីអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការស្តាប់ចម្លើយទាំងឡាយដែលបានធ្វើឡើងជាមួយសាក្សីនៃសំណុំរឿង ០០២ នៅក្នុងកិច្ចស៊ើបសួរ ក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ ("សំណើ")[1]។ សំណើនេះត្រូវបានដាក់ជាថា សាធារណៈ និងបានជូនដំណឹងដល់សហចៅក្រមអង្កេត ដែលមានឧបសម្ព័ន្ធសម្ងាត់បំផុតមួយភ្ជាប់ជាមួយ ដោយកំណត់អត្តសញ្ញាណសាក្សីពាក់ព័ន្ធចំនួន២៩នាក់។ សាក្សីទាំងនេះ ត្រូវបានជ្រើសរើសមកផ្តល់សក្ខីកម្មផ្ទាល់មាត់ដោយអង្គជំនុំជម្រះសាលាដំបូង ឬបានស្នើឡើងដោយសហព្រះរាជអាជ្ញាដើម្បីមកបំភ្លឺ ឬទទួលយកកំណត់ហេតុរបស់ពួកគាត់ជាភស្តុតាងនៅពេលសវនាការជំនុំជម្រះ។

២. ដូចបានកត់សម្គាល់ក្នុងសំណើ តាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងវិធាននីតិវិធី ដែលបានកំណត់នៅថ្នាក់អន្តរជាតិសម្រាប់ករណីស្រដៀងគ្នានេះ កំណត់ហេតុសាក្សីដូច្នេះត្រូវបានតម្រូវឱ្យដាក់បង្ហាញដោយសំអាងលើមូលដ្ឋានថា (១) អាចមានសម្ភារៈដោះបន្ទុក ឬសម្ភារៈដែលអាចមានអនុភាពទៅលើភាពជឿទុកចិត្តបាននៃសក្ខីកម្មរបស់សាក្សីណាម្នាក់ និង (២) ដែលជាកំណត់ហេតុពីមុនៗរបស់សាក្សីណាម្នាក់នៅពេលសវនាការជំនុំជម្រះ។

៣. នៅក្នុងអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២[2] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> *វិធាន៥៣(៤)នៃវិធានផ្ទៃក្នុងបានដាក់តម្រូវ នូវកាតព្វកិច្ចមួយជាបន្តទៀតដល់សហព្រះរាជអាជ្ញាដែលត្រូវបង្ហាញជូនដល់អង្គជំនុំជម្រះសាលាដំបូង នូវឯកសារណាមួយដែលស្ថិតនៅក្នុងការកាន់កាប់របស់ខ្លួន ដែលអាចនឹងបង្ហាញឱ្យឃើញអំពីភាពស្លូតត្រង់ ឬការសម្រាលទោសដល់ជនជាប់ចោទ ឬ ដែលប៉ះពាល់ដល់ភាពអាចឱ្យជឿទុកចិត្តបាន នៃភស្តុតាង។ គឺដើម្បីផលប្រយោជន៍ ក្នុងការនាំទៅរកការបង្ហាញការពិតនោះហើយដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវមានសិទ្ធិក្នុងការចូលទៅពិនិត្យមើលនូវឯកសារទាំងនេះដែលមិនត្រូវឱ្យខកខានទេ ព្រោះការពិចារណាទៅលើចម្លើយពីមុនៗនឹងជួយនៅក្នុងការវាយតម្លៃអំពីការជឿទុកចិត្តទៅលើសាក្សីទាំងនេះ។*

---

[1] **E127** ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត, ៦ តុលា ២០១១ ជាមួយនឹង **E127.2** ឧបសម្ព័ន្ធ ក សម្ងាត់បំផុត, ៦ តុលា ២០១១។

[2] ឯកសារលេខ **E127/4** ការបង្ហាញជូននូវចម្លើយសាក្សីសម្រាប់សាក្សីទាំងឡាយដែលអាចត្រូវធ្វើសក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៤ មករា ២០១២។

៤. ហេតុដូចនេះ អង្គជំនុំជម្រះ បានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយនានារបស់សាក្សីទាំង២៩ នាក់ដែលមានអត្តសញ្ញាណដូចនៅក្នុងសំណើសុំ ព្រមជាមួយនឹងខ្សែអាត់ថតសម្លេងដែលពាក់ព័ន្ធផង ហើយត្រូវជូនដំណឹងអំពីកិច្ចការទាំងអស់នេះដល់អង្គជំនុំជម្រះជាបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋានការសម្ងាត់បំផុត។ ជាបន្ថែមពីលើនេះ អង្គជំនុំជម្រះបានបញ្ជាក់ថែមទៀតថា ករណីបើសិនជាសហព្រះរាជអាជ្ញាបានទទួលដំណឹងអំពីចម្លើយនានាបន្ថែមទៀតពីសាក្សីដែលនៅក្នុងសំណុំរឿងលេខ០០២ ដែលស្រង់បានដោយសហចៅក្រមស៊ើបអង្កេត ដែលជាប់ទាក់ទងនឹងសំណុំរឿងមួយផ្សេងទៀត ចម្លើយទាំងនោះគួរត្រូវបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូងតាមរបៀបដដែលដូចគ្នានេះ។

៥. ដោយគោរពតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង និងដោយមិនមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាអន្តរជាតិ សូមដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុស្តាប់ចម្លើយទាំងអស់ដែលធ្វើឡើងដោយសាក្សីទាំង ២៩ នាក់ ដែលមាននៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ (ដូចដែលបានរៀបរាប់ក្នុងបញ្ជីនៅក្នុង **ឧបសម្ព័ន្ធ ក**) និង សំណុំឯកសារស្តាប់ចម្លើយនីមួយៗដែលថតជាសម្លេង (ដូចដែលបានរៀបរាប់ក្នុងបញ្ជីនៅក្នុង **ឧបសម្ព័ន្ធ ខ**)។ កំណត់ហេតុស្តាប់ចម្លើយ និង សំណុំឯកសារស្តាប់ចម្លើយដែលថតជាសម្លេងទាំងនេះ ក៏ត្រូវបានភ្ជាប់មកជាមួយ និងមានជាស្រេចទុកសម្រាប់ផ្តល់ជូនទៅអង្គជំនុំជម្រះក្នុងលក្ខណៈជាការសម្ងាត់បំផុតផងដែរ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |